ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 04-Nov-21, 14:00
CMS/CFO: Sann Rada

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC/SC

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen Harding CLARK
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២១
ភាសាដើម៖ ខ្មែរ/អង់គ្លេស
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ:

---

# សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំចេញដីកាបង្គាប់ដើម្បីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងដោយប្រសិទ្ធភាព និងការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌

---

**ដាក់ដោយ**

ពេជ អង្គ

Megan HIRST

**ទល់នឹង**

ការិយាល័យរដ្ឋបាល

តូនី ក្រាញ់

Knut Rosandhaug

**<u>ចម្លងជូន</u>**

ជា លាង

Brenda HOLLIS

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

**<u>មេធាវីការពារក្តី</u>**

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” ឬ“អង្គជំនុំជម្រះ” និង “អ.វ.ត.ក” នីមួយៗ)

**បានទទួល**សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំចេញដីកាបង្គាប់ការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការទទួលបានតំណាងដោយប្រសិទ្ធភាព និងការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌ (“សំណើបន្ទាន់”)[1] និងសារណាតបរបស់ការិយាល័យរដ្ឋបាល (“ការិយាល័យរដ្ឋបាល”)[2]

**កត់សម្គាល់ឃើញ**ថា សំណើបន្ទាន់នេះស្នើសុំការធ្វើអន្តរាគមន៍ពីអង្គជំនុំជម្រះចេញដីកាបង្គាប់ការិយាល័យរដ្ឋបាល “ទទួលស្គាល់ត្រឹមត្រូវនូវអាណត្តិរបស់សហមេធាវីនាំមុខតាមវិធាន ១២*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង” និង“ធានាផ្តល់ធនធានសម្រាប់ចំណាត់ការលើសកម្មភាពទាំងឡាយនៅក្នុងអាណត្តិនោះសម្រាប់ផ្នែកបន្ទាប់នៃសំណុំរឿង ០០២”[3]

**រំលឹក**ថា អង្គជំនុំជម្រះបានសម្រេចរួចរាល់ហើយលើខ្លឹមនៃបញ្ហានេះ ដោយបានសន្និដ្ឋានថា “ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរដ្ឋបាលនៅក្នុងដែននៃសិទ្ធិអំណាចរបស់ការិយាល័យរដ្ឋបាល អាស្រ័យហេតុនេះ ពុំមែនជាបញ្ហាដែលអាចជំនុំជម្រះបាន និងពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ”[4]

**កត់សម្គាល់ឃើញ**ថា សំណើបច្ចុប្បន្ននេះពាក់ព័ន្ធទៅនឹងបញ្ហាដដែលស្នើសុំបន្តកិច្ចសន្យាការងាររបស់មន្ត្រីប្រឹក្សាច្បាប់អន្តរជាតិមួយរូប និងពុំឃើញមានព័ត៌មានថ្មីគាំទ្រការលើកឡើងថា ការមិនបន្តកិច្ចសន្យា

[1] ឯកសារលេខ F70 ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២១។

[2] សារណាតបរបស់ការិយាល័យរដ្ឋបាលទៅនឹងសំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ F70/1 ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០២១។

[3] សំណើបន្ទាន់ កថាខណ្ឌ ១ និង ១០៩។

[4] សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់ឯកសារមួយភាសា និងការពន្លឿនកាលវិភាគដាក់ឯកសារ ឯកសារលេខ F69/1 ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០២១។

ការងារនៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ នឹងធ្វើឱ្យការធ្វើជាតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (និងកិច្ចដំណើរការនីតិវិធីត្រឹមត្រូវយុត្តិធម៌) ពុំអាចធ្វើទៅបាន”[5]

**កត់សម្គាល់ឃើញថា** អនុលោមតាមវិធាន ១២ *ស្ទួនពីរ* និង ២៣ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយសហមេធាវីនាំមុខពីររូប និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងថាអង្គភាពរបស់ សហមេធាវីនាំមុខ ត្រូវបានគាំទ្រដោយមន្ត្រីច្បាប់ពីររូប[6]

**ដោយបានពិចារណាពេញលេញ**លើសំណើបន្ទាន់នេះ

**ពិចារណាឃើញថា** អង្គជំនុំជម្រះតុលាការកំពូលត្រូវបានផ្ដល់ឱ្យនូវយុត្តាធិការលើបណ្ដឹងសាទុក្ខស្ដីពីបញ្ហាអង្គច្បាប់ និងអង្គហេតុស្របតាមក្របខ័ណ្ឌគតិយុត្តិ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក.

**សន្និដ្ឋានថា** សំណើបន្ទាន់នេះពាក់ព័ន្ធទៅនឹងសេចក្ដីសម្រេចរដ្ឋបាលនៅក្នុងដែននៃសិទ្ធិអំណាចរបស់ការិយាល័យរដ្ឋបាល ហេតុដូច្នេះ ពុំមែនជាបញ្ហាដែលអាចជំនុំជម្រះបាន និងពុំស្ថិតក្នុងវិសាលភាពនៃយុត្តាធិការរបស់អង្គជំនុំជម្រះតុលាការកំពូល និងនៅគ្រប់កាលៈទេសៈទាំងអស់ ពុំមានការបង្ហាញណាមួយដែលថា សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានការតំណាង និងការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌ត្រូវបាន ឬនឹងត្រូវបានរំលោភបំពានឡើយ

**អាស្រ័យហេតុនេះ៖**

សម្រេច**បដិសេធ**សំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០២១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**

[5] សំណើបន្ទាន់ កថាខណ្ឌ ៣។

[6] សារណាតបរបស់ការិយាល័យរដ្ឋបាល កថាខណ្ឌ ៣។